សុន្ទរកថារបស់ **ឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព
របស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយ
សំរាប់គម្រោងទ្រង់ទ្រាយតូចផ្នែកវប្បធម៌
៧ មិនា ២០១៥

- **សូមគោរព ឯកឧត្តម សាមីឌី ស៊ីវឌ្ឍនា អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា**
- **សូមគោរព លោក ណាំង វ៉ារុធ ប្រធានសមាគមអៃគីដូកម្ពុជា**
- **សូមគោរព លោក ហុក ឈាងគីម អគ្គលេខាធិការសហព័ន្ធកីឡាល្បុក្កតោកម្ពុជា**
- **សូមគោរព លោក យាន ងួន ប្រធានសហព័ន្ធគូប៊ូដូ និង យោដូកម្ពុជា**
- **សូមគោរព លោក អ៊ីហ្សាគី ហ៊ីរ៉ូស៊ី ប្រធានតំណាងអង្គការ JICA នៅកម្ពុជា**
- **សូមគោរព អស់លោក លោកស្រី!**

ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្សរីករាយ ដើម្បីប្រារព្ធពិធីចុះហត្ថលេខាផ្តល់ជំនួយឧបត្ថម្ភ សម្រាប់គម្រោងទ្រង់ទ្រាយតូចផ្នែកវប្បធម៌ “គម្រោងសាងសង់មជ្ឈមណ្ឌលក្បាច់គុនបុរាណកម្ពុជា-ជប៉ុននៅភ្នំពេញ” ផ្តល់ជូនដល់សមាគមអៃគីដូកម្ពុជា ។

ដើម្បីលើកស្ទួយវិស័យសិល្បៈក្បាច់គុនបុរាណកម្ពុជា-ជប៉ុន សមាគមអៃគីដូកម្ពុជា នឹងអនុវត្តគម្រោងសាងសង់មជ្ឈមណ្ឌលក្បាច់គុនបុរាណកម្ពុជា-ជប៉ុននៅភ្នំពេញ។ រដ្ឋាភិបាលជប៉ុន បានផ្តល់ថវិកាសរុបចំនួន ១០២,៧៨០ ដុល្លាអាមេរិក ដល់សមាគមអៃគីដូកម្ពុជាសម្រាប់គម្រោងនេះ។

វិស័យកីឡា បានរួមចំណែកយ៉ាងសកម្មដល់ការធ្វើអោយប្រសើរឡើងនូវសុខភាព ជាពិសេសចំពោះយុវជន។ ជាមួយគ្នានេះកម្ពុជា មានកម្មវិធីអប់រំកាយសម្បទា និងអភិវឌ្ឍន៍វិស័យកីឡា ដែលមាននៅក្នុងផែនការយុទ្ធសាស្ត្រនៃការអប់រំ និងមាននិន្នាការលើកកម្ពស់វិស័យកីឡាផងដែរ។ នៅខណៈនេះ ខ្ញុំមានសេចក្តីសប្បាយរីករាយ ដែលក្បាច់គុនជប៉ុន ជាក្បាច់គុនសម្រាប់បណ្តុះបណ្តាលទាំងកាយសម្បទា និងស្មារតី ហើយដែលឆ្លុះបញ្ចាំងពីសីលធម៌ និងការគួរសមឱនលំទោននោះ បានទាក់ទាញប្រជាជនកម្ពុជាជាច្រើនអោយចូលមកហាត់រៀននាពេលថ្មីៗនេះ ហើយប្រជាជនកម្ពុជាជាច្រើន ក៏ពេញចិត្តនឹងក្បាច់គុនជប៉ុន ដែលជាក្បាច់គុនមិនប្រកាន់អាយុ និងភេទនេះផងដែរ។

ជាងនេះទៅទៀតនោះ សិល្បៈក្បាច់គុននេះ បានឆ្លុះបញ្ចាំងពីប្រវត្តិសាស្ត្រ និង វប្បធម៌ជាច្រើនរបស់ប្រទេស ហើយគឺជាការល្អប្រសើរណាស់ ដែលប្រជាជនជប៉ុន និងប្រជាជនកម្ពុជាព្យាយាមយល់ពីវប្បធម៌គ្នាទៅវិញទៅមក តាមរយៈក្បាច់គុនបុរាណ ខណៈពេលដែលសហគមន៍ជនជាតិជប៉ុន មានចំនួនកើនឡើងយ៉ាងរហ័សនៅក្នុងប្រទេសកម្ពុជា។

រដ្ឋាភិបាលជប៉ុន បានគាំទ្រវិស័យកីឡាកម្ពុជា តាមរយៈគម្រោងជាច្រើនរួមមាន គម្រោងសាងសង់មជ្ឈមណ្ឌលសម្រាប់ហ្វឹកហាត់កីឡា ការផ្គត់ផ្គង់សំភារៈបរិក្ខារកីឡា និងការបញ្ជូនអ្នកស្ម័គ្រចិត្ត ព្រមទាំងអ្នកស្ម័គ្រចិត្តជាន់ខ្ពស់ជប៉ុនរបស់JICA មកកម្ពុជា។ សម្រាប់សមាគមអៃគីដូកម្ពុជាយើង បានបញ្ជូនអ្នកស្ម័គ្រចិត្តរបស់ JICA មកធ្វើការជាមួយអស់រយៈពេលប្រមាណជា ១0ឆ្នាំមកហើយ។ ហើយយើង ក៏បានអនុវត្តប្រកបដោយជោគជ័យនូវកម្មវិធីផ្លាស់ប្តូររវាងប្រទេសជប៉ុន និងប្រទេសកម្ពុជា តាមរយៈវិស័យកីឡាដូចជា កម្មវិធីផ្លាស់ប្តូរយុវជន“JENESYS2.0”ជាដើម។ យើងនឹងធ្វើការគាំទ្រគម្រោងទាំងនេះជាបន្តទៅទៀត ជាមួយនឹងការទទួលស្គាល់គុណប្រយោជន៍នៃការលេងកីឡាដោយធ្វើការហ្វឹកហាត់ និងការទំនាក់ទំនងជាមួយគ្នា។ ជាពិសេសនៅក្នុងឆ្នាំ២០២០ កីឡាអូឡាំពិក និងប៉ារ៉ាឡាំពិកនឹងប្រារព្ធនៅទីក្រុងតូក្យូ ហើយនៅក្នុងឆ្នាំ២០២៣ ការប្រកួតស៊ីហ្គេម ក៏នឹងត្រូវប្រារព្ធនៅក្នុងប្រទេសកម្ពុជាផងដែរ។ ដូច្នេះ ខ្ញុំសង្ឃឹមថា ការផ្លាស់ប្តូរវិស័យកីឡារវាងប្រទេសជប៉ុន និងប្រទេសកម្ពុជា នឹងកាន់តែមានប្រជាប្រិយភាពឡើង។

ជាចុងក្រោយនេះ ជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចផ្នែកវប្បធម៌ ដែលអនុវត្តគម្រោងវប្បធម៌ និងគម្រោងការអប់រំថ្នាក់ឧត្តមសិក្សា នឹងផ្តល់អត្ថប្រយោជន៍ដល់ប្រជាជននៅតាមកម្រិតមូលដ្ឋាន។ ខ្ញុំសង្ឃឹមថា មជ្ឈមណ្ឌលក្បាច់គុនបុរាណកម្ពុជា-ជប៉ុន នឹងផ្តល់អត្ថប្រយោជន៍ជូនសិល្បៈករក្បាច់គុនកម្ពុជា និងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពដែលមានស្រាប់រួចមកហើយរវាងប្រជាជនជប៉ុន និង ប្រជាជនកម្ពុជា។

**សូមអរគុណ!**